**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ.០១៣.....សហវ.[illegible]

# សារាចរ
# ស្តីពី
# ការអនុវត្តគោលការណ៍ និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការបែងចែករំលែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

កន្លងមក ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការបែងចែករំលែកចំណូលមិនមែនសារពើពន្ធ ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុវត្ត អនុលោមតាមប្បញ្ញត្តិនៃលិខិតគតិយុត្តនានា ដែលរួមមានជាអាទិ៍ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ អនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ អនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ប្រកាសរួម និង ប្រកាសអន្តរក្រសួងពាក់ព័ន្ធនឹងការបែងចែកចំណូលពីសេវាសាធារណៈ និងការពិន័យរបស់ក្រសួង ស្ថាប័ន ប្រកាស លេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ សារាចរណែនាំលេខ០១០ សហវ.អហក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីគោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវារដ្ឋបាល នៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសារាចរណែនាំលេខ០០១ សហវ ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០១៨ ស្តីពីកិច្ចបញ្ជិកាគណនេយ្យរជ្ជទេយ្យ ចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ សារាចរលេខ០០៦ សហវ. ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូលពីកម្រៃសេវា របស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញជុំវិញរាជធានី ខេត្ត។

ថ្មីៗនេះ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍ និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការបែងចែករំលែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលគ្រោងអនុវត្តជាផ្លូវការចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ តទៅ។ ក្នុងគោលបំណងធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព នៃការអនុវត្ត


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

ប្បញ្ញត្តិ នៃអនុក្រឹត្យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរ អង្គភាពជំនាញជុំវិញរាជធានី ខេត្ត មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត និងរតនាគាររាជធានី ខេត្ត អំពីការអនុវត្តគោលការណ៍ និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការបែងចែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានអានុភាពអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ និងមានខ្លឹមសារដូចតទៅ៖

## ១. គោលការណ៍រួម

មុខសញ្ញាចំណូលមិនមែនសារពើពន្ធ ក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការបែងចែកចំណូលមិនមែនសារពើពន្ធ ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន ចំណូលពីសេវាសាធារណៈ ចំណូលពីការពិន័យ និងការដាក់ទណ្ឌកម្ម ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និង/ឬ ចំណូលមិនមែនសារពើពន្ធផ្សេងទៀត តាមការសម្រេចរបស់រាជរដ្ឋាភិបាល។ ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងក្របខ័ណ្ឌនេះ អាចត្រូវបានធ្វើឡើងតាមរយៈ៖

- ការផ្ទេរសិទ្ធិអំណាចជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងការគ្រប់គ្រង និងប្រមូលចំណូលមិនមែនសារពើពន្ធផ្សារភ្ជាប់មុខងារដែលបានផ្ទេរពីរដ្ឋបាលថ្នាក់ជាតិ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងរូបភាពជាការប្រគល់មុខងារ ឬ ការធ្វើប្រតិភូកម្មមុខងារ
- ការបែងចែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និង
- ទម្រង់ផ្សេងទៀត តាមការសម្រេចរបស់រាជរដ្ឋាភិបាល។

ក្រសួង ស្ថាប័នដែលសម្រេចផ្ទេរមុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើសទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់នូវគោលបំណងនៃការផ្ទេរនោះឱ្យបានច្បាស់លាស់ ជាការប្រគល់មុខងារ ឬជាការធ្វើប្រតិភូកម្មមុខងារ ឱ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅណាមួយ ដែលជារដ្ឋបាលរាជធានី ខេត្ត ឬ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬ រដ្ឋបាលឃុំ សង្កាត់។

## ២. ការគ្រប់គ្រងចំណូលពីសេវាសាធារណៈ និង ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម ក្នុងក្របខ័ណ្ឌនៃការប្រគល់មុខងារ

### ២.ក. ការប្រគល់មុខងារ-ទទួលមុខងារ

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានការប្រគល់មុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើសមួយចំនួនពីក្រសួង ស្ថាប័ន នឹងក្លាយជាម្ចាស់មុខងារថ្មី ដែលជាមុខងារផ្ទាល់របស់ខ្លួន។

ក្រសួង ស្ថាប័នដែលបានប្រគល់មុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើសមួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ត្រូវរៀបចំកែសម្រួលប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ ដោយលុបប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើសទាំងនោះ ចេញពីប្រកាសរួម ឬ ប្រកាសអន្តរក្រសួង។

ក្រសួងមហាផ្ទៃ ក្នុងនាមជាស្ថាប័នដឹកនាំ គ្រប់គ្រង សម្របសម្រួល គាំទ្រ និងតាមដាន ត្រួតពិនិត្យ វាយតម្លៃលើរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលទទួលបានការប្រគល់មុខងារគ្រប់គ្រង និងការប្រមូលចំណូលពី

ប្រភេទសេវាសាធារណៈ ឬ ចំណូលពីប្រភេទអំពើល្មើស ត្រូវរៀបចំកែសម្រួលប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយដាក់បញ្ចូលប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើសទាំងនោះ ទៅក្នុងកម្រងសេវាសាធារណៈ ឬ បញ្ជីផាកពិន័យរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួង។ ក្នុងករណីមានការកែប្រែតម្លៃសេវា ឬ កម្រិតទឹកប្រាក់ផាកពិន័យ ត្រូវមានការពិគ្រោះយោបល់ពីក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ។ គំរូប្រកាសអន្តរក្រសួង ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ២.ខ. ការរៀបចំគម្រោងចំណូល-ចំណាយ និងគម្រោងតម្រូវការបរិមាណបង្កាន់ដៃបង់ប្រាក់ប្រចាំឆ្នាំ

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានការប្រគល់មុខងារលើការគ្រប់គ្រង និងការប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ចំណូលពីប្រភេទអំពើល្មើស ត្រូវរៀបចំគម្រោងចំណូល-ចំណាយ និងគម្រោងតម្រូវការបរិមាណបង្កាន់ដៃបង់ប្រាក់ប្រចាំឆ្នាំ ដូចខាងក្រោម៖

- គ្រោងឥណទានចំណូល ១០០ (មួយរយ) ភាគរយ នៅក្នុងគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់ខ្លួន
- គ្រោងឥណទានចំណាយសម្រាប់ទូទាត់ប្រាក់រង្វាន់ ផ្អែកតាមអត្រាប្រាក់រង្វាន់តាមគោលការណ៍កំណត់ ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅក្នុងគម្រោងចំណាយថវិកាប្រចាំឆ្នាំរបស់ខ្លួន និង
- រៀបចំគម្រោងតម្រូវការបរិមាណបង្កាន់ដៃបង់ប្រាក់ប្រចាំឆ្នាំ សម្រាប់ការប្រមូលចំណូលប្រចាំឆ្នាំដែលបានគ្រោង។

## ២.គ. ការអនុវត្តការប្រមូលចំណូល-ចំណាយ

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានការប្រគល់មុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើសមួយចំនួន ត្រូវ៖

- អនុវត្តការប្រមូលចំណូលផ្អែកតាមតម្លៃសេវា ឬ កម្រិតទឹកប្រាក់ផាកពិន័យ ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ក្នុងរយៈពេលអន្តរកាល នៃការរៀបចំកែសម្រួលប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅពុំទាន់រួចរាល់ អនុវត្តការប្រមូលចំណូលផ្អែកតាមតម្លៃសេវា ឬ កម្រិតទឹកប្រាក់ផាកពិន័យ តាមប្រកាសរួម ឬ ប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ
- ប្រើប្រាស់បង្កាន់ដៃបង់ប្រាក់របស់រដ្ឋបាលសាមី ដែលបោះពុម្ព និងបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងករណីទទួលចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬ ជាមូលប្បទានបត្រ។ ក្នុងករណីទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក មិនតម្រូវឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់នេះទេ
- ទទួលបណ្ណបង់ប្រាក់ ឬ ប្រកាសឥណទានចេញដោយធនាគារពាណិជ្ជ ឬ ភ្នាក់ងារផ្ទេរប្រាក់ផ្សេងទៀត ក្នុងករណីទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក

- បែងចែកចំណូលប្រមូលបានប្រចាំខែ ផ្អែកតាមអត្រា និងមុខសញ្ញាគោលដៅនីមួយៗ ទៅតាមគោលការណ៍ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ក្នុងរយៈពេលអន្តរកាល នៃការរៀបចំកែសម្រួលប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅពុំទាន់រួចរាល់ ត្រូវអនុវត្តការបែងចែកចំណូលផ្អែកតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ចាត់វិធានការតឹងទារដោយការបញ្ជូនសំណុំរឿងទៅសាលាជម្រះក្តី ក្នុងករណីបុគ្គលប្រព្រឹត្តល្មើស មានការរឹងរូសមិនព្រមបង់ប្រាក់ផាកពិន័យ។ ចំណូលដែលប្រមូលបានដោយអនុវត្តតាមសេចក្តីសម្រេចរបស់សាលាជម្រះក្តី ត្រូវកត់ត្រាជាចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសាមីដែលជាអ្នកចាត់វិធានការបញ្ជូនសំណុំរឿងទៅសាលាជម្រះក្តី។ ដូចគ្នាដែរ ចំពោះសំណុំរឿងជាប្រភេទបទល្មើសព្រហ្មទណ្ឌ ចំណូលពីការផ្តន្ទាទោសពិន័យជាប្រាក់ដែលសម្រេចដោយសាលាជម្រះក្តី ត្រូវកត់ត្រាជាចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសាមី ដែលជាអ្នកចាត់វិធានការបញ្ជូនសំណុំរឿងទៅសាលាជម្រះក្តី
- ត្រូវរៀបចំសលាកបត្របង្វែរចំណូលថវិកា នូវទឹកប្រាក់ចំណូលដែលខ្លួនបានប្រមូល និងបានបង់ចូលគណនីចរន្តរបស់រតនាគាររាជធានី ខេត្តនៅធនាគារពាណិជ្ជដៃគូ ចូលថវិការបស់ខ្លួន និង
- ទូទាត់ប្រាក់រង្វាន់តាមរយៈអាណត្តិបើកប្រាក់ (អាណត្តិនិយ័តកម្ម) ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះក្នុងសលាកបត្របង្វែរចំណូលថវិកា និងភ្ជាប់មកជាមួយនូវសក្ខីបត្រចំណាយឱ្យបានត្រឹមត្រូវ។

## ២.ឃ. ការកត់ត្រាតាមដាន និងការរៀបចំរបាយការណ៍

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានការប្រគល់មុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើសមួយចំនួន ត្រូវទទួលខុសត្រូវលើការទុកដាក់ថែរក្សាលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យដោយចុះកិច្ចបញ្ជិកាទ្វេភាគនូវរាល់កិច្ចប្រតិបត្តិការដែលកើតឡើងប្រចាំថ្ងៃ ទៅតាមនីតិវិធីគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិវិធីពាក់ព័ន្ធដទៃទៀត តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

នៅរៀងរាល់ដំណាច់ខែ រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានការប្រគល់មុខងារគ្រប់គ្រង និងប្រមូលចំណូលលើប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើស ត្រូវផ្ញើបណ្ណបង់ប្រាក់ និងសលាកបត្របង្វែរចំណូលថវិកា ដែលជាច្បាប់ថតចម្លងចំនួនមួយច្បាប់ ទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីតាមដានការអនុវត្តចំណូល។

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានការប្រគល់មុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើសមួយចំនួន ត្រូវធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ស្តីពីស្ថានភាពនៃការអនុវត្តចំណូល ដូចប្រភេទចំណូលដែលជាមុខងារផ្ទាល់របស់ខ្លួន រួចផ្ញើទៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត និងផ្ញើទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីធ្វើរបាយការណ៍បូកសរុប ឱ្យបានមុនៈ

- ថ្ងៃទី១៥ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ
- ថ្ងៃទី១៥ នៃខែដើមត្រីមាសបន្ទាប់ សម្រាប់របាយការណ៍ប្រចាំត្រីមាស
- ថ្ងៃទី១៥ ខែកក្កដា សម្រាប់របាយការណ៍ប្រចាំឆមាសទី១ និង
- ថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

គំរូរបាយការណ៍ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ៣. ការគ្រប់គ្រងចំណូលពីសេវាសាធារណៈ និង ចំណូលពីការពិន័យនិងការដាក់ទណ្ឌកម្ម ក្នុងក្របខ័ណ្ឌនៃការធ្វើប្រតិភូកម្មមុខងារ

### ៣.ក. ការធ្វើប្រតិភូកម្មមុខងារ-ទទួលបានប្រតិភូកម្មមុខងារ

ក្រសួង ស្ថាប័នដែលធ្វើប្រតិភូកម្មមុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើស ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ នៅតែរក្សាភាពជាម្ចាស់លើមុខងារនោះដដែល។ រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានប្រតិភូកម្មមុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើសមួយចំនួនពីក្រសួង ស្ថាប័ន ត្រូវអនុវត្តមុខងារ ដោយផ្អែកតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើស ដែលក្រសួង ស្ថាប័ន បានធ្វើប្រតិភូកម្មមុខងារគ្រប់គ្រង និងប្រមូលចំណូលទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នៅតែត្រូវបានរក្សាទុកនៅក្នុងកម្រងសេវាសាធារណៈ ឬ បញ្ជីផាកពិន័យរបស់ក្រសួង ស្ថាប័នសាមី ដែលកំណត់ដោយប្រកាសរួម ឬ ប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ។ គំរូប្រកាសអន្តរក្រសួង ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានប្រតិភូកម្មមុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើស ត្រូវអនុវត្តការប្រមូលចំណូលផ្អែកតាមតម្លៃសេវា ឬ កម្រិតទឹកប្រាក់ផាកពិន័យ ដែលកំណត់ដោយប្រកាសរួម ឬ ប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ។ ក្នុងករណីមានការកែប្រែតម្លៃសេវា ឬ កម្រិតទឹកប្រាក់ផាកពិន័យ ត្រូវមានការចូលរួមពិគ្រោះយោបល់ពីក្រសួងមហាផ្ទៃ។

### ៣.ខ. ការរៀបចំគម្រោងចំណូល-ចំណាយ និងគម្រោងតម្រូវការបរិមាណបង្កាន់ដៃបង់ប្រាក់ប្រចាំឆ្នាំ

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានប្រតិភូកម្មមុខងារលើការគ្រប់គ្រង និងការប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ចំណូលពីប្រភេទអំពើល្មើស ត្រូវរៀបចំគម្រោងចំណូល-ចំណាយ គម្រោងតម្រូវការបរិមាណបង្កាន់ដៃបង់ប្រាក់ប្រចាំឆ្នាំ ដូចខាងក្រោម៖

- គ្រោងឥណទានចំណូល ១០០ (មួយរយ) ភាគរយ នៅក្នុងគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់ខ្លួន
- គ្រោងឥណទានចំណាយសម្រាប់ទូទាត់ប្រាក់រង្វាន់ ផ្អែកតាមអត្រាប្រាក់រង្វាន់តាមគោលការណ៍កំណត់ដោយប្រកាសរួម ឬ ប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ នៅក្នុងគម្រោងចំណាយថវិកាប្រចាំឆ្នាំរបស់ខ្លួន និង

- រៀបចំគម្រោងតម្រូវការបរិមាណបង្កាន់ដៃបង់ប្រាក់ប្រចាំឆ្នាំ សម្រាប់ការប្រមូលចំណូលប្រចាំឆ្នាំដែលបានគ្រោង។

### ៣.គ. ការអនុវត្តការប្រមូលចំណូល-ចំណាយ

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានប្រតិភូកម្មមុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើសមួយចំនួន ត្រូវ៖

- អនុវត្តការប្រមូលចំណូលផ្អែកតាមតម្លៃសេវា ឬ កម្រិតទឹកប្រាក់ផាកពិន័យ ដែលកំណត់ដោយប្រកាសរួម ឬ ប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ
- ប្រើប្រាស់បង្កាន់ដៃបង់ប្រាក់របស់រដ្ឋបាលសាមី ដែលបោះពុម្ព និងបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងករណីទទួលចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬ ជាមូលប្បទានបត្រ។ ក្នុងករណីទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក មិនតម្រូវឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់នេះទេ
- ទទួលបណ្ណបង់ប្រាក់ ឬ ប្រកាសឥណទានចេញដោយធនាគារពាណិជ្ជ ឬ ភ្នាក់ងារផ្ទេរប្រាក់ផ្សេងទៀត ក្នុងករណីទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក
- បែងចែកចំណូលប្រមូលបានប្រចាំខែ ផ្អែកតាមអត្រា និងមុខសញ្ញាគោលដៅនីមួយៗ ទៅតាមគោលការណ៍ដែលកំណត់ដោយប្រកាសរួម ឬ ប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ត្រូវរៀបចំសលាកបត្របង្វែរចំណូលថវិកា នូវទឹកប្រាក់ចំណូលដែលខ្លួនបានប្រមូលនិងបានបង់ចូលគណនីចរន្តរបស់រតនាគាររាជធានី ខេត្តនៅធនាគារពាណិជ្ជដៃគូ ចូលថវិការបស់ខ្លួន និង
- ទូទាត់ប្រាក់រង្វាន់តាមរយៈអាណត្តិបើកប្រាក់ (អាណត្តិនិយ័តកម្ម) ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះក្នុងសលាកបត្របង្វែរចំណូលថវិកា និងភ្ជាប់មកជាមួយនូវសក្ខីបត្រចំណាយឱ្យបានត្រឹមត្រូវ។

### ៣.ឃ. ការកត់ត្រាតាមដាន និងការរៀបចំរបាយការណ៍

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ដែលទទួលបានប្រតិភូកម្មមុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើស ត្រូវទទួលខុសត្រូវលើការទុកដាក់ថែរក្សាលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យដោយចុះកិច្ចបញ្ជិកាទ្វេភាគនូវរាល់កិច្ចប្រតិបត្តិការដែលកើតឡើងប្រចាំថ្ងៃ ទៅតាមនីតិវិធីគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិវិធីពាក់ព័ន្ធដទៃទៀត តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

នៅរៀងរាល់ដំណាច់ខែ រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ដែលទទួលបានប្រតិភូកម្មមុខងារគ្រប់គ្រងនិងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើស ត្រូវផ្ញើបណ្ណបង់ប្រាក់ និងសលាកបត្របង្វែរចំណូលថវិកា ដែលជាច្បាប់ថតចម្លងចំនួនមួយច្បាប់ ទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីតាមដានការអនុវត្តចំណូល។



4~~v

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលទទួលបានប្រតិភូកម្មមុខងារគ្រប់គ្រង និងប្រមូលចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើស ត្រូវធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំស្តីពីស្ថានភាពនៃការអនុវត្តចំណូល ទៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត នៃក្រសួង ស្ថាប័នដែលជាម្ចាស់មុខងារ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ឱ្យបានមុនៈ

- ថ្ងៃទី១៥ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ
- ថ្ងៃទី១៥ នៃខែដើមត្រីមាសបន្ទាប់ សម្រាប់របាយការណ៍ប្រចាំត្រីមាស
- ថ្ងៃទី១៥ ខែកក្កដា សម្រាប់របាយការណ៍ប្រចាំឆមាសទី១ និង
- ថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

គំរូរបាយការណ៍ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មន្ទីរ អង្គភាពជំនាញជុំវិញរាជធានី ខេត្ត នៃក្រសួង ស្ថាប័នដែលជាម្ចាស់មុខងារ ត្រូវធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំស្តីពីស្ថានភាពនៃការអនុវត្តចំណូលពីប្រភេទសេវាសាធារណៈ ឬ ប្រភេទអំពើល្មើសដែលបានធ្វើប្រតិភូកម្មមុខងារនោះ ផ្ញើទៅក្រសួង ស្ថាប័នរបស់ខ្លួន ឱ្យបានមុនៈ

- ថ្ងៃទី២០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ
- ថ្ងៃទី២០ នៃខែដើមត្រីមាសបន្ទាប់ សម្រាប់របាយការណ៍ប្រចាំត្រីមាស
- ថ្ងៃទី២០ ខែកក្កដា សម្រាប់របាយការណ៍ប្រចាំឆមាសទី១ និង
- ថ្ងៃទី២០ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

គំរូរបាយការណ៍ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ៤. ការគ្រប់គ្រងការបែងចែកចំណូលពីសេវាសាធារណៈពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

### ៤.ក. វិសាលភាពនៃការបែងចែកចំណូលពីសេវាសាធារណៈ

ក្រសួង ស្ថាប័ន ដែលប្រមូលចំណូលពីសេវាសាធារណៈ ត្រូវបែងចែកចំណូលពីសេវាសាធារណៈដែលប្រមូលបាននៅរដ្ឋបាលកណ្តាល ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រៅពីប្រភេទចំណូលពីសេវាសាធារណៈដែលបានផ្ទេរមុខងាររួចហើយ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងចំណូលពីសេវាសាធារណៈ ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញជុំវិញរាជធានី ខេត្ត។

ក្រសួង ស្ថាប័នដែលប្រមូលចំណូលពីសេវាសាធារណៈ ត្រូវបន្តគ្រប់គ្រងទាំងស្រុងលើចំណូលពីសេវាសាធារណៈ ដែលត្រូវបែងចែកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្រសួង ស្ថាប័នដែលប្រមូលចំណូលពីសេវាសាធារណៈ ត្រូវបែងចែកចំណូលពីសេវាសាធារណៈដែលប្រមូលបាននៅរដ្ឋបាលកណ្តាល ផ្អែកតាមអត្រាដូចមានកំណត់ក្នុងលិខិតគតិយុត្តជាធរមាន ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការផ្ទេរចូល **«មូលនិធិភាគរភាព»**។

អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំវិភាជថវិកាតាមរយៈយន្តការ **«មូលនិធិភាគរភាព»** ឱ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅនីមួយៗ ក្នុងនោះការយកចិត្ត

ទុកដាក់ខ្ពស់ត្រូវផ្តល់លើរដ្ឋបាលក្រុង ស្រុក និង រដ្ឋបាលឃុំ សង្កាត់ នៅក្នុងការគ្រោងចំណូល និងឥណទានចំណាយថវិកា នៅក្នុងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

### ៤.ខ. ការរៀបចំគម្រោងចំណូល-ចំណាយ និងគម្រោងតម្រូវការបរិមាណបង្កាន់ដៃបង់ប្រាក់ប្រចាំឆ្នាំ

ក្រសួង ស្ថាប័ន ដែលត្រូវចែករំលែកចំណូលពីសេវាសាធារណៈ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវ៖

- គ្រោងឥណទានចំណូល ១០០ (មួយរយ) ភាគរយ នៅក្នុងគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់ខ្លួន
- គ្រោងឥណទានចំណាយលើទឹកប្រាក់ចំណូល ដែលគ្រោងចែករំលែកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈមូលនិធិភាគរភាព ផ្អែកតាមអត្រាដូចមានកំណត់ក្នុងលិខិតគតិយុត្តជាធរមាន។ ការគណនារកឥណទានចំណាយនេះ ត្រូវផ្អែកទៅតាមសមាមាត្រ នៃចំណែកសាច់ប្រាក់ដែលត្រូវបង់ចូលគណនីទោលរតនាគារ ដូចមានចែងក្នុងប្រកាសរួម ឬ ប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ ទៅតាមមុខសញ្ញាចំណូលពីសេវាសាធារណៈ ដែលបានគ្រោងក្នុងគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់ខ្លួន និង
- រៀបចំគម្រោងតម្រូវការបរិមាណបង្កាន់ដៃបង់ប្រាក់ប្រចាំឆ្នាំ សម្រាប់ការប្រមូលចំណូលប្រចាំឆ្នាំដែលបានគ្រោង។

### ៤.គ. ការអនុវត្តការប្រមូលចំណូល-ចំណាយ

ក្រសួង ស្ថាប័ន ដែលត្រូវចែករំលែកចំណូលពីសេវាសាធារណៈ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវ៖

- អនុវត្តការប្រមូលចំណូលផ្អែកតាមតម្លៃសេវា ឬ កម្រិតទឹកប្រាក់ផាកពិន័យ តាមប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ
- ប្រើប្រាស់បង្កាន់ដៃបង់ប្រាក់របស់ក្រសួង ស្ថាប័នសាមី ដែលបោះពុម្ព និងបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងករណីទទួលចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬ ជាមូលប្បទានបត្រ។ ក្នុងករណីទូទាត់ ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក មិនតម្រូវឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់នេះទេ
- ទទួលបណ្ណបង់ប្រាក់ ឬ ប្រកាសឥណទានចេញដោយធនាគារពាណិជ្ជ ឬ ភ្នាក់ងារផ្ទេរប្រាក់ផ្សេងទៀត ក្នុងករណីទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក
- ផ្ទេរចំណូលចែករំលែកទៅក្នុងមូលនិធិភាគរភាព ផ្អែកតាមអត្រាដូចមានកំណត់ក្នុងលិខិតគតិយុត្តជាធរមាន ។ ការគណនារកចំណូលដែលត្រូវផ្ទេរចូលមូលនិធិភាគរភាព ត្រូវផ្អែកទៅតាមសមាមាត្រនៃចំណែកសាច់ប្រាក់ដែលបានបង់ចូលគណនីទោលរតនាគារជាក់ស្តែង ដោយក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ ទៅតាមមុខសញ្ញាចំណូលពីសេវាសាធារណៈដែលប្រមូលបានប្រចាំឆ្នាំជាក់ស្តែង
- ជារៀងរាល់ដំណាច់ឆមាស ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ ដើម្បីកត់ត្រាចំណាយទឹកប្រាក់ចំណូលជាក់ស្តែង ដែលត្រូវចែករំលែក និងផ្ទេរចូលមូលនិធិភាគរភាព
- ក្នុងករណីចំណូលប្រមូលបានលើសផែនការ ក្រសួង ស្ថាប័ន ត្រូវស្នើសុំបន្ថែមឥណទាន ដើម្បីបោះផ្សាយ អាណត្តិបើកប្រាក់ ផ្ទេរចូលមូលនិធិភាគរភាព។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងរៀបចំ

ប្រកាសបន្ថែមឥណទានជំពូក៦៥ ទៅតាមទំហំឥណទានដែលអនុវត្តលើសជាក់ស្តែង ជូនក្រសួង ស្ថាប័ន

- ត្រូវរៀបចំសលាកបត្របង្វែរចំណូលថវិកានូវទឹកប្រាក់ចំណូលដែលខ្លួនបានប្រមូល និងបានបង់ចូលគណនីទោលរតនាគារនៅធនាគារជាតិនៃកម្ពុជា ឬ គណនីចរន្តរបស់អគ្គនាយកដ្ឋានរតនាគារជាតិនៅធនាគារពាណិជ្ជដៃគូ ចូលថវិកាថ្នាក់ជាតិរបស់ខ្លួន និង
- ទូទាត់ប្រាក់រង្វាន់តាមរយៈអាណត្តិបើកប្រាក់ (អាណត្តិនិយ័តកម្ម) ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះក្នុងសលាកបត្របង្វែរចំណូលថវិកា និងភ្ជាប់មកជាមួយនូវសក្ខីប័ត្រចំណាយឱ្យបានត្រឹមត្រូវ។

### ៤.ឃ. ការកត់ត្រាតាមដាន និងការរៀបចំរបាយការណ៍

ក្រសួង ស្ថាប័ន ដែលចែករំលែកចំណូលពីសេវាសាធារណៈ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវលើការទុកដាក់ថែរក្សាលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យដោយចុះកិច្ចបញ្ជិកាទ្វេភាគនូវរាល់កិច្ចប្រតិបត្តិការ ដែលកើតឡើងប្រចាំថ្ងៃ ទៅតាមនីតិវិធីគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួង ស្ថាប័ន ដែលចែករំលែកចំណូលពីសេវាសាធារណៈ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើរបាយការណ៍អនុវត្តចំណូលដែលត្រូវចែករំលែក ដោយឆ្លុះបញ្ចាំងនូវទឹកប្រាក់ជាក់ស្តែងដែលបានចែករំលែក និងបានផ្ទេរចូលមូលនិធិភាតរភាព ផ្ញើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបានមុនៈ

- ថ្ងៃទី១៥ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ
- ថ្ងៃទី១៥ នៃខែដើមត្រីមាសបន្ទាប់ សម្រាប់របាយការណ៍ប្រចាំត្រីមាស
- ថ្ងៃទី១៥ ខែកក្កដា សម្រាប់របាយការណ៍ប្រចាំឆមាសទី១ និង
- ថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

គំរូរបាយការណ៍ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ៥. ការគ្រប់គ្រងការចែករំលែកចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

### ៥.ក. វិសាលភាពនៃការចែករំលែកចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ

ក្រសួង ស្ថាប័នដែលមានចុះលិខិតគតិយុត្តបង្កើតចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ នៅតែមានតួនាទីនិងសិទ្ធិអំណាច ក្នុងការគ្រប់គ្រងផ្នែកបច្ចេកទេស ស្របតាមបទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ រួមទាំងត្រួតពិនិត្យតាមដានការអនុវត្តលិខិតគតិយុត្តបង្កើតចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងការគ្រប់គ្រងទទួលខុសត្រូវលើចំណូល ១០០ (មួយរយ) ភាគរយដដែល ទោះបីចំណូលមួយផ្នែក ឬទាំងស្រុង ត្រូវបានចែករំលែកជូនរដ្ឋបាលថ្នាក់ក្រោមជាតិហើយក៏ដោយ។

ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋដែលចែករំលែកពីរដ្ឋបាលថ្នាក់ជាតិ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន ចំណូលពីសម្បទាននេសាទ ចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរជំនាញ រាជធានី ខេត្ត ចំណូលពី

សម្បទានដីសេដ្ឋកិច្ច ចំណូលពីផលព្រៃឈើ និង/ឬ ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋផ្សេងទៀត ដែលមានការសម្រេចពីរាជរដ្ឋាភិបាល។

ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវចែករំលែកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្តល់ចំណែកជាអាទិភាព ជូនរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដែលចូលរួមកៀរគរចំណូលដោយផ្ទាល់នៅក្នុងរដ្ឋបាលដែនដី។

ចំណូលចែករំលែកមួយចំណែកទៀត ដែលនៅសល់ក្រោយការចែករំលែកជូនរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ត្រូវផ្ទេរជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ដោយអនុវត្តតាមយន្តការ **«មូលនិធិភាតរភាព»**។ អត្រានៃការបែងចែកចំណូលចែករំលែករវាង រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ និងតាមរយៈយន្តការ **«មូលនិធិភាតរភាព»** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ។

### ៥.ខ. ការរៀបចំគម្រោងចំណូល - ចំណាយ

ក្រសួង ស្ថាប័នដែលចែករំលែកចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅត្រូវរៀបចំផែនការគ្រោងចំណូល ដែលនៅសល់ក្រោយការចែករំលែកឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ទៅក្នុងគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់ខ្លួន។

ក្រសួង ស្ថាប័ន ត្រូវគ្រោងឥណទានចំណាយលើទឹកប្រាក់ចំណូល ដែលគ្រោងចែករំលែក និងផ្ទេរទៅមូលនិធិភាតរភាព ទៅតាមអត្រាដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ដែលទទួលបានចំណូលពីការចែករំលែកចំណូលពីការចាត់ចែងទ្រព្យ-សម្បត្តិរដ្ឋ ត្រូវរៀបចំផែនការគ្រោងចំណូលបានពីការចែករំលែកនោះទៅតាមអត្រាដែលកំណត់ ទៅក្នុងគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់ខ្លួន។

### ៥.គ. ការអនុវត្តការប្រមូលចំណូល-ចំណាយ

ក្រសួង ស្ថាប័នដែលចែករំលែកចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ និង ចូលទៅក្នុងមូលនិធិភាតរភាព ត្រូវប្រមូលចំណូល ១០០ (មួយរយ) ភាគរយ ដែលកំណត់ក្នុងលិខិតគតិយុត្តបង្កើតចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ។ ក្រោយពីប្រមូលចំណូលបាន ក្រសួង ស្ថាប័នត្រូវចាត់ចែងបែងចែកចំណូលនោះ ទៅរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ និងទៅមូលនិធិភាតរភាព ទៅតាមអត្រាកំណត់ក្នុងលិខិតគតិយុត្តជាធរមាន និងប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួង ស្ថាប័ន ត្រូវរៀបចំសលាកបត្របង្វែរចំណូលថវិកា ចូលថវិកាថ្នាក់ជាតិ នូវចំណែកក្រោយពីចែករំលែកទៅរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ។

ក្រសួង ស្ថាប័ន ត្រូវបោះផ្សាយអាណត្តិនូវចំណែកផ្ទេរទៅមូលនិធិភាតរភាព នៅរៀងរាល់ឆមាស។

ក្រសួង ស្ថាប័ន ក្រោយពីចាត់ចែងបែងចែកចំណូលដែលខ្លួនប្រមូលបានរួចរាល់ ត្រូវជូនដំណឹងទៅរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ដើម្បីរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅមានមូលដ្ឋានរៀបចំសលាកបត្របង្វែរចំណូលថវិកា នូវចំណែកដែលខ្លួនទទួលបានចូលថវិកាថ្នាក់ក្រោមជាតិគោលដៅរបស់ខ្លួន។

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ដែលទទួលបានចំណូលពីការចែករំលែក នៃចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ត្រូវរៀបចំសលាកបត្របង្វែរចំណូលថវិកា ចូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ នូវចំណែកដែលខ្លួនទទួលបាន។

ក្នុងករណីចំណូលប្រមូលបានលើសផែនការ ក្រសួង ស្ថាប័នដែលមានចុះលិខិតគតិយុត្តបង្កើតចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ត្រូវស្នើសុំបន្ថែមឥណទាន ដើម្បីបោះផ្សាយអាណត្តិបើកប្រាក់ផ្ទេរចូលមូលនិធិភាគរភាព។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងរៀបចំប្រកាសបន្ថែមឥណទានជំពូក៦៥ ទៅតាមទំហំឥណទានដែលអនុវត្តលើសជាក់ស្តែង ជូនក្រសួងស្ថាប័ន។

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ត្រូវសហការជាមួយក្រសួង ស្ថាប័នដែលចុះលិខិតគតិយុត្តបង្កើតចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ក្នុងការជំរុញការបង់ចំណូល និងប្រមូលចំណូល ១០០ (មួយរយ) ភាគរយ ដែលកំណត់ក្នុងលិខិតគតិយុត្តបង្កើតចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ។

## ៥.ឃ. ការត្រួតពិនិត្យតាមដានការអនុវត្តលិខិតគតិយុត្តបង្កើតចំណូលពីទ្រព្យ-សម្បត្តិរដ្ឋ

ក្រសួង ស្ថាប័នដែលមានចុះលិខិតគតិយុត្តបង្កើតពីការចាត់ចែងចំណូលពីទ្រព្យសម្បត្តិរដ្ឋ ត្រូវទទួលខុសត្រូវក្នុងការតាមដាន ការអនុវត្តលិខិតគតិយុត្តបង្កើតចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ត្រួតពិនិត្យកាតព្វកិច្ចរបស់ភាគីឯកជន និងជំរុញការបង់ចំណូល ១០០ (មួយរយ) ភាគរយ ដែលកំណត់ក្នុងលិខិតគតិយុត្តបង្កើតចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ។

រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ដែលមានចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋស្ថិតក្នុងដែនសមត្ថកិច្ចរដ្ឋបាលសាមី ត្រូវចូលរួមសហការជាមួយក្រសួង ស្ថាប័ន ក្នុងការត្រួតពិនិត្យការអនុវត្តលិខិតគតិយុត្តបង្កើតចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋកាតព្វកិច្ចរបស់ភាគីឯកជន និងជំរុញការបង់ចំណូល ១០០ (មួយរយ) ភាគរយដែលកំណត់ក្នុងលិខិតគតិយុត្តបង្កើតចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ។

## ៥.ង. ការកត់ត្រាតាមដាន និងការរៀបចំរបាយការណ៍

ផ្អែកតាមតួលេខបង់ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋនៅរតនាគាររាជធានី ខេត្ត រដ្ឋបាលថ្នាក់ក្រោម-ជាតិគោលដៅ ត្រូវធ្វើរបាយការណ៍អំពីការបង់ចំណូល ១០០ (មួយរយ) ភាគរយ តាមលិខិតគតិយុត្តបង្កើតចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងចំណូលដែលប្រមូលបានជាក់ស្តែង ជូនក្រសួង ស្ថាប័នដែលចុះលិខិតគតិយុត្តបង្កើតចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និង អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុន៖

- ថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ
- ថ្ងៃទី១០ នៃខែដើមត្រីមាសបន្ទាប់ សម្រាប់របាយការណ៍ប្រចាំត្រីមាស
- ថ្ងៃទី១០ ខែកក្កដា សម្រាប់របាយការណ៍ប្រចាំឆមាសទី១ និង
- ថ្ងៃទី១០ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

ផ្អែកតាមតួលេខបង់ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋនៅអគ្គនាយកដ្ឋានរតនាគារជាតិ និងរបាយ-ការណ៍អំពីការបង់ចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ក្រសួង ស្ថាប័នដែលប្រមូលចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ត្រូវធ្វើរបាយការណ៍អំពីការបង់ចំណូល ១០០ (មួយរយ) ភាគរយ តាមលិខិតគតិយុត្តបង្កើតចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និង ចំណូលដែលប្រមូលបានជាក់ស្តែង រួចត្រូវផ្ញើមកអគ្គនាយកដ្ឋាន

ទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបានមុនៈ

- ថ្ងៃទី១៥ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ
- ថ្ងៃទី១៥ នៃខែដើមត្រីមាសបន្ទាប់ សម្រាប់របាយការណ៍ប្រចាំត្រីមាស
- ថ្ងៃទី១៥ ខែកក្កដា សម្រាប់របាយការណ៍ប្រចាំឆមាសទី១ និង
- ថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

ផ្អែកតាមគួលេខបង់ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋនៅរតនាគាររាជធានី ខេត្ត រដ្ឋបាលថ្នាក់ក្រោម-ជាតិគោលដៅ ដែលទទួលចំណូលចែករំលែកពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ត្រូវធ្វើរបាយការណ៍ផ្ញើជូនសាមីក្រសួង ស្ថាប័នដែលចែករំលែកចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងផ្ញើជូនអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបានមុនៈ

- ថ្ងៃទី២០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ
- ថ្ងៃទី២០ នៃខែដើមត្រីមាសបន្ទាប់ សម្រាប់របាយការណ៍ប្រចាំត្រីមាស
- ថ្ងៃទី២០ ខែកក្កដា សម្រាប់របាយការណ៍ប្រចាំឆមាសទី១ និង
- ថ្ងៃទី២០ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

## ៦. សន្ធានកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រង និងការប្រមូលចំណូលមិនមែនសារពើពន្ធ

ក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការចែករំលែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើការកត់ត្រាចំណូល និងរៀបចំសាលា-កបត្របង្វែរចំណូលនៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (ហៅកាត់ថា NRMIS) ស្របតាមនីតិវិធី ដែលបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

អង្គភាពទទួលបន្ទុកប្រព័ន្ធ NRMIS នៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើបច្ចុប្បន្នកម្មប្រព័ន្ធ NRMIS ស្របតាមខ្លឹមសារ នៃសារាចរនេះ ដើម្បីឱ្យក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិអាចអនុវត្តបានពេញលេញប្រកបដោយប្រសិទ្ធភាព។

ចំពោះក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបាន និងកំពុងអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងផ្ទាល់ខ្លួន ដែលមានការពាក់ព័ន្ធទៅនឹងចំណូលមិនមែនសារពើពន្ធ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់-ក្រោមជាតិទាំងនោះ ត្រូវធ្វើសន្ធានកម្មទិន្នន័យជាមួយប្រព័ន្ធ NRMIS ដោយសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ។ បន្ថែមពីនេះ ក្រសួង ស្ថាប័ន ត្រូវធ្វើសន្ធានកម្មទិន្នន័យជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រង និងផ្តល់សេវាសាធារណៈ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ចំពោះប្រភេទសេវាសាធារណៈដែលបានប្រគល់ ឬ ប្រតិភូកម្មមុខងារគ្រប់គ្រងនិងប្រមូលចំណូល ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៧. កិច្ចបញ្ជិកាគណនេយ្យ

ការចុះកិច្ចបញ្ជិកាគណនេយ្យសម្រាប់ចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការបែងចែករំលែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុលោមទាំងស្រុងតាមសារាចរណែនាំលេខ០០១ សហវ ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០១៨ ស្តីពីកិច្ចបញ្ជិកាគណនេយ្យរដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងសារាចរលេខ០០៦ សហវ. ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូលពីកម្រៃសេវា របស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញជុំវិញរាជធានី ខេត្ត និងបទប្បញ្ញត្តិជាធរមាន។

ទទួលបានសារាចរនេះ គ្រប់អង្គភាពក្រោមឱវាទក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត និងរតនាគាររាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុវិញ។

ថ្ងៃ ខែ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត
- រតនាគាររាជធានី ខេត្ត
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ